# យុទ្ធនាការ #ដោះលែងអ្នកទាំង៥ សូមស្វាគមន៍ការដោះលែងអ្នកការពារសិទ្ធិមនុស្សទាំង៥ បន្ទាប់ពីពួកគេត្រូវបានជាប់ឃុំឃាំងអស់រយៈពេលជាង ១៤ ខែ និងអំពាវនាវឲ្យទម្លាក់រាល់ការចោទប្រកាន់លើពួកគេ

**ភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧** យុទ្ធនាការ ដោះលែងអ្នកទាំង៥ សូមស្វាគមន៍ការដោះលែងអ្នកការពារសិទ្ធិមនុស្សទាំង ៥ លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វង់ដា អ្នកស្រី លឹម មុន្នី និងលោក នី ចរិយា បន្ទាប់ពីរយៈពេល ៤២៧ ថ្ងៃនៃការឃុំខ្លួនតាមអំពើចិត្ត និងជំរុញឲ្យអាជ្ញាធរទម្លាក់រាល់ការចោទប្រកាន់លើពួកគេ។

យើងខ្ញុំមានសេចក្ដីរីករាយ ដែលបានឃើញសហការី និងមិត្តភក្ដិរបស់យើងខ្ញុំមានសេរីភាពវិញ និងបានជួបជុំជាមួយអ្នកជាទីស្រលាញ់របស់ពួកគេ។ អស់រយៈពេលមួយឆ្នាំជាងមកហើយ ដែលពួកគេត្រូវរងទុក្ខដោយសារតែការបែកបាក់ពីក្រុមគ្រួសាររបស់ពួកគេ ត្រូវរស់នៅក្នុងពន្ធនាគារក្នុងលក្ខខណ្ឌដ៏លំបាក និងការបដិសេធសំណើសុំនៅក្រៅឃុំជាបន្តបន្ទាប់ ថ្វីបើអាជ្ញាធរខកខានក្នុងការផ្ដល់នូវភស្តុតាងដែលអាចជឿជាក់បានដើម្បីបញ្ជាក់ពីការបន្តការឃុំខ្លួនរបស់ពួកគេក៏ដោយ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ លោក ជាម ច័ន្ទពិសិដ្ឋ ជាចៅក្រមស៊ើបសួរក្នុងសំណុំរឿងរបស់ពួកគេ បានចេញដីកាដំណោះស្រាយ ដោយបញ្ជូនរឿងក្ដីនេះទៅចៅក្រមជំនុំជម្រះ។ បុគ្គលិករបស់សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគមអាដហុក) រងការចោទប្រកាន់ពីបទសូកប៉ាន់សាក្សី ចំណែកឯ លោក នី ចរិយា ក៏ត្រូវរងការចោទប្រកាន់ពីបទសមគំនិត ក្នុងបទល្មើសដូចខាងលើ។ ស្របពេលជាមួយគ្នានោះ ចៅក្រមស៊ើបសួរបានសម្រេចដោះលែងអ្នកទាំង៥ ពីការឃុំខ្លួន ដោយដាក់លក្ខខណ្ឌចំនួនបីគឺ ៖ អ្នកទាំង៥ មិនត្រូវផ្លាស់ប្ដូរទីលំនៅ ដោយគ្មានការអនុញ្ញាតពីតុលាការ អ្នកទាំង៥ មិនត្រូវធ្វើដំណើរទៅក្រៅប្រទេស ដោយគ្មានការអនុញ្ញាតពីតុលាការ និងពួកគេត្រូវតែបង្ហាញមុខនៅតុលាការពេលដែលមានដីកាកោះហៅ។

ខណៈដែលយើងស្វាគមន៍ការដោះលែងរបស់អ្នកទាំង៥ ពីពន្ធនាគារ ថាជាជំហានវិជ្ជមាន ប៉ុន្តែពួកគេមិនគួរត្រូវបានឃុំខ្លួនតាំងពីដំបូងមកម្លេះ។ ការសម្រេចឃុំខ្លួនពួកគេបណ្ដោះអាសន្ន ពុំមានមូលដ្ឋានច្បាប់ច្បាស់លាស់ ទាំងនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ហើយក៏ពុំមានភស្តុតាងជាក់លាក់ណាមួយដែលបានបង្ហាញថា មានលក្ខខណ្ឌចាំបាច់ណាមួយក្នុងការឃុំខ្លួនពួកគេបណ្ដោះអាសន្ន ដូចមានចែងក្នុង មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ហើយការព្រួយបារម្ភទាំងឡាយ ក៏គួរតែអាចកាត់បន្ថយបានតាមរយៈការដាក់លក្ខខណ្ឌមកលើការអនុញ្ញាតឲ្យពួកគេនៅក្រៅឃុំ។[1]

[1] វិភាគផ្នែកច្បាប់រួម ជុំវិញការឃុំខ្លួនបណ្ដោះអាសន្នលើ លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វង់ដា អ្នកស្រី លឹម មុន្នី និងលោក នី ចរិយា (ខែវិច្ឆិកា ២០១៦) http://bit.ly/2g4Zuxw

យើងសូមអំពាវនាវឲ្យអាជ្ញាធរទម្លាក់រាល់ការចោទប្រកាន់ដោយគ្មានមូលដ្ឋាន មកលើអ្នកទាំង៥ និងស្នើសុំឲ្យមានការសម្រេចសាជាថ្មីទៅលើ រឿងក្តីបរិហារកេរ្តិ៍របស់ លោក នី ចរិយា ផងដែរ។[2] យើងនឹងបន្តអំពាវនាវឲ្យមានការដោះលែង សកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្ស អ្នកស្រី ទេព វន្នី ដែលមកទល់ថ្ងៃនេះបានចំណាយពេល ៣១៩ ថ្ងៃហើយក្នុងពន្ធនាគារ បន្ទាប់ពីអ្នកស្រីត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ខណៈពេលដែលធ្វើការតវ៉ាដើម្បីឲ្យមានការដោះលែងអ្នកទាំង៥។

[2] សេចក្តីថ្លែងការណ៍រួម ៖ "អង្គការសង្គមស៊ីវិលសូមសម្តែងការមិនពេញចិត្ត ចំពោះការតម្កល់សេចក្តីសម្រេចផ្តន្ទាទោសលើលោក នី ចរិយា ដែលជាអ្នកការពារសិទ្ធិមនុស្ស (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦) http://bit.ly/2sthkQb